**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ១៥. អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលបៀវត្សមូលដ្ឋាននិងការបើកផ្តល់បៀវត្ស ដល់មន្ត្រីនគរបាលជាតិកម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ៨៩ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលប្រព័ន្ធបៀវត្សនគរបាលជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

### សម្រេច

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងដើម្បីរៀបចំការកំណត់បៀវត្សមូលដ្ឋាន និង ការបើកផ្តល់បៀវត្សមូលដ្ឋាននិងរបបឧបត្ថម្ភផ្សេងៗដល់មន្ត្រីនគរបាលជាតិកម្ពុជា។


www.pheakdeylaw.com

**មាត្រា២ .-**

អនុក្រឹត្យនេះ មានគោលដៅកំណត់៖

- កម្រិតសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីនគរបាលជាតិកម្ពុជា
- ការបើកផ្តល់បៀវត្សមូលដ្ឋាននិងរបបឧបត្ថម្ភផ្សេងៗរបស់មន្ត្រីនគរបាលជាតិតាមប្រព័ន្ធធនាគារ លើកលែងមន្ត្រីនគរបាលជាតិ ដែលមានការអនុញ្ញាតដោយឡែកដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា៣ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះមន្ត្រីនគរបាលជាតិកម្ពុជា។

**មាត្រា៤ .-**

បៀវត្សមូលដ្ឋានរបស់មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវបានរៀបចំបែងចែកតាមលំដាប់នៃឋានន្តរស័ក្តិ និងត្រូវបានផ្តល់នូវកម្រិតសន្ទស្សន៍ ដូចមានកំណត់ក្នុងតារាងខាងក្រោម៖

| ល.រ | ឋានន្តរស័ក្តិ | កម្រិតសន្ទស្សន៍បៀវត្សមូលដ្ឋាន |
|---|---|---|
| ១ | នាយឧត្តមសេនីយ៍ | ៥៥០ |
| ២ | ឧត្តមសេនីយ៍ឯក | ៥៣១ |
| ៣ | ឧត្តមសេនីយ៍ទោ | ៥១៣ |
| ៤ | ឧត្តមសេនីយ៍ត្រី | ៤៩៦ |
| ៥ | វរសេនីយ៍ឯក | ៤៧៩ |
| ៦ | វរសេនីយ៍ទោ | ៤៦១ |
| ៧ | វរសេនីយ៍ត្រី | ៤៤៣ |
| ៨ | អនុសេនីយ៍ឯក | ៤០៧ |
| ៩ | អនុសេនីយ៍ទោ | ៣៨០ |
| ១០ | អនុសេនីយ៍ត្រី | ៣៥៥ |
| ១១ | នាយចំណង់ | ៣៣១ |
| ១២ | ព្រឹន្ទបាលឯក | ៣១៨ |
| ១៣ | ព្រឹន្ទបាលទោ | ៣០០ |
| ១៤ | ពលបាលឯក | ២៨៤ |
| ១៥ | ពលបាលទោ | ២៧៤ |
| ១៦ | ពលបាលត្រី | ២៦៥ |

កម្រិតសន្ទស្សន៍បៀវត្សមូលដ្ឋានខាងលើ ត្រូវចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥។



www.pheakdeylaw.com

**មាត្រា៥ .-**

តម្លៃឯកតាសន្ទស្សន៍សម្រាប់អនុវត្តនិងការកែប្រែតម្លៃឯកតាសន្ទស្សន៍ ត្រូវអនុវត្តតាមអនុក្រឹត្យស្តីពីតម្លៃឯកតានៃសន្ទស្សន៍សម្រាប់បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល។

**មាត្រា៦ .-**

មន្ត្រីនគរបាលជាតិដែលមានសិទ្ធិទទួលបៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ ប្រាក់វិភាជន៍គ្រួសារ ប្រាក់ហូបប្រចាំថ្ងៃ និងរបបអង្ករប្រចាំខែ ព្រមទាំងរបបឧបត្ថម្ភផ្សេងទៀត ត្រូវស្ថិតក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- កំពុងបំពេញការងារក្នុងក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- កំពុងផ្លាស់ប្តូរកន្លែងធ្វើការនិងកំពុងធ្វើដំណើរទៅកាន់មុខតំណែងនៅក្នុងឬក្រៅប្រទេស
- កំពុងបំពេញការសិក្សាក្នុងឬក្រៅប្រទេសតាមតម្រូវការរបស់នគរបាលជាតិ
- មន្ត្រីនគរបាលជាតិពលី ពិការ មរណៈ និវត្តជន បាត់បង់សមត្ថភាពការងារដែលមិនទាន់ផ្ទេរទៅឱ្យក្រសួងទទួលបន្ទុកអតីតយុទ្ធជនគ្រប់គ្រងបន្ត
- មន្ត្រីនគរបាលជាតិដែលទទួលការអនុញ្ញាតច្បាប់ក្នុងចុះផ្ទាល់ រយៈពេលសម្រាកព្យាបាលជម្ងឺ និងបាត់ខ្លួនក្នុងបេសកកម្ម។

**មាត្រា៧ .-**

ការបញ្ឈប់ការបើកផ្តល់បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ ប្រាក់វិភាជន៍គ្រួសារ ប្រាក់ហូបប្រចាំថ្ងៃ និងរបបអង្ករប្រចាំខែ ព្រមទាំងរបបឧបត្ថម្ភផ្សេងទៀត ត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងករណីដូចខាងក្រោម៖

- មន្ត្រីនគរបាលជាតិដែលសុំលាឈប់ពីការងារដោយមានការអនុញ្ញាត
- មន្ត្រីនគរបាលជាតិដែលមានប្រកាសបណ្តេញចេញពីក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- មន្ត្រីនគរបាលជាតិដែលអវត្តមានគ្មានការអនុញ្ញាតឬហួសកំណត់ដោយសម្អាងលើប្រធានស័ក្តិដែលមិនសមស្រប
- មន្ត្រីនគរបាលជាតិពលី ពិការ មរណៈ និវត្តជន បាត់បង់សមត្ថភាពការងារដែលបានផ្ទេរទៅឱ្យក្រសួងទទួលបន្ទុកអតីតយុទ្ធជនគ្រប់គ្រងបន្តរួចហើយ
- មន្ត្រីនគរបាលជាតិដែលមានសាលក្រមរបស់តុលាការបញ្ជាក់ថាជាទណ្ឌិត។

**មាត្រា៨ .-**

របបឧបត្ថម្ភផ្សេងៗរបស់មន្ត្រីនគរបាលជាតិក្រៅពីបៀវត្សមូលដ្ឋាន ត្រូវបន្តអនុវត្តរហូតដល់មានការកែប្រែជាថ្មី។

**មាត្រា៩ .-**

បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ ប្រាក់វិភាជន៍គ្រួសារ ប្រាក់ហូបប្រចាំថ្ងៃ រួមទាំងរបបអង្ករប្រចាំខែដែលគិតជាសាច់ប្រាក់ត្រូវបើកផ្តល់ដល់មន្ត្រីនគរបាលជាតិតាមប្រព័ន្ធធនាគារ។

ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ត្រូវសហការរៀបចំការបើកផ្តល់បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ ប្រាក់វិភាជន៍គ្រួសារ ប្រាក់ហូបប្រចាំថ្ងៃ រួមទាំងរបបអង្ករប្រចាំខែគិតជាសាច់ប្រាក់ដល់មន្ត្រីនគរបាលជាតិតាមប្រព័ន្ធធនាគារឱ្យបានរួចរាល់ក្នុងឆ្នាំ២០១៥។

ក្នុងករណីសេវាធនាគារនៅមិនទាន់មាននៅជិតអង្គភាព ដើម្បីបង្កភាពងាយស្រួលដល់ការបើកផ្តល់បៀវត្សដល់មន្ត្រីនគរបាលជាតិម្នាក់ៗ ក្រសួងមហាផ្ទៃនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំសារាចរណែនាំស្តីពីការបើកផ្តល់បៀវត្សពីធនាគារដល់មន្ត្រីនគរបាលជាតិនៅតាមអង្គភាពនោះ។



www.pheakdeylaw.com

**មាត្រា១០ .-**

អនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលប្រាក់បៀវត្សរ៍មូលដ្ឋានរបស់មន្ត្រីនគរបាលជាតិ ត្រូវទុកជានិរាករណ៍។

**មាត្រា១១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០១៥

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

| | | |
|---|---|---|
| **ឧបនាយករដ្ឋមន្ត្រី**<br>**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** | **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | **រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ** |
| **ស ខេង** | **អូន ព័ន្ធមុនីរ័ត្ន** | **ពេជ្រ ប៊ុនធិន** |

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com